TIGER
TEACHING FOR IMPROVED GENDER EQUALITY AND RESPONSIVENESS

# ការចូលរួមរបស់មាតាបិតា និងសហគមន៍មូលដ្ឋាននៅក្នុងសាលារៀន





## ការចូលរួមរបស់មាតាបិតា និងសហគមន៍ធ្វើឱ្យ







## ហេតុអ្វីការចូលរួមរបស់មាតាបិតា និងសហគមន៍ជាការចាំបាច់ចំពោះសាលារៀន ?

សាលារៀនតែមួយមុខមិនអាចធានាការអប់រំសម្រាប់កុមារបានទេ ប៉ុន្តែគឺជាការទទួលខុសត្រូវរួមរបស់ សាលារៀន គ្រួសារ និង សហគមន៍មូលដ្ឋាន ។







## តើឪពុកម្តាយ ឬអាណាព្យាបាលចូលរួមជាមួយសាលាដោយរបៀបណា ?


ជាផ្នែកមួយនៃគណៈគ្រប់គ្រងសាលា


តាមដានការសិក្សារៀនសូត្ររបស់សិស្ស


ចូលរួមកសាងផែនការ/អនុវត្តផែនការសាលា


ថែរក្សាទ្រព្យសម្បត្តិសាលា


ចែករំលែកបទពិសោធន៍ និងបំណិនជីវិត


ស្វែងរកធនធាន និងទទួលបានពត៌មានចំណូលចំណាយ


ចូលរួមទប់ស្កាត់ ការពារនិងដោះស្រាយបញ្ហាក្នុង និងក្រៅសាលារៀន

## សារៈប្រយោជន៍នៃទំនាក់ទំនងរវាងសាលារៀន និងសហគមន៍



ការបង្រៀន និងអប់រំកុមារឱ្យបានល្អ



ផ្តល់ឱ្យសហគមន៍នូវចំណេះដឹងថ្មីៗ



បង្កើនទំនាក់ទំនងល្អរវាងសហគមន៍ និងសាលារៀន



ងាយស្រួលកៀរគរធនធានដើម្បីអភិវឌ្ឍសាលារៀន



មានការទទួលស្គាល់ និងគាំទ្រពីសហគមន៍ និងអាជ្ញាធរមូលដ្ឋាន



គ្រូមានទំនាក់ទំនងល្អ ជាមួយមាតាបិតាសិស្ស




សាលារៀនមានសុវត្ថិភាពសម្រាប់កុមារ



គុណភាពអប់រំត្រូវបានកែលម្អ




កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា

## ប្រភេទនៃការចូលរួមទាំង៦ របស់មាតាបិតា

**ការចិញ្ចឹមកូន៖** ជួយគ្រួសារនូវបំណិនក្នុងការចិញ្ចឹមកូនបែបវិជ្ជមាន ការជួយគាំទ្រគ្រួសារ ការស្វែងយល់ពីការលូតលាស់របស់កុមារ និងជំទង់ និងការរៀបចំលក្ខខណ្ឌផ្ទះសម្បែងដើម្បីគាំទ្រការសិក្សារៀនសូត្រ ជួយសាលារៀនឱ្យស្វែងយល់ពីប្រវត្តិ និងវប្បធម៌របស់គ្រួសារសិស្ស និងគោលដៅរបស់កុមារ។

**ការទំនាក់ទំនង៖** ការទំនាក់ទំនងជាមួយគ្រួសារសិស្សអំពីកម្មវិធីសាលារៀន និងការរីកចម្រើនរបស់សិស្ស។ បង្កើតមធ្យោបាយទំនាក់ទំនងទៅវិញទៅមកដែលមានប្រសិទ្ធភាព និងអាចទុកចិត្តបានរវាងគ្រួសារសិស្ស និងសាលារៀន។

**ការសិក្សានៅផ្ទះ៖** អញ្ជើញគ្រួសារសិស្សឱ្យចូលរួមជាមួយកូនៗរបស់ពួកគាត់ក្នុងសកម្មភាពរៀនសូត្រនៅផ្ទះ រួមមានការធ្វើកិច្ចការផ្ទះដែលគ្រូបានដាក់ឱ្យ ការកំណត់គោលដៅ និងសកម្មភាពផ្សេងៗទៀតដែលពាក់ព័ន្ធនឹងកម្មវិធីសិក្សា។

**ការស្ម័គ្រចិត្ត៖** កែលម្អការជ្រើសរើស និងការបំប៉នដើម្បីទាក់ទាញការចូលរួមរបស់គ្រួសារសិស្សជាអ្នកស្ម័គ្រចិត្ត និងជាអ្នកទស្សនានៅឯសាលារៀន។ ជំរុញឱ្យអ្នកអប់រំសហការជាមួយអ្នកស្ម័គ្រចិត្តដែលជួយគាំទ្រសិស្ស និងសាលារៀន។ ផ្តល់ការងារដែលមានប្រយោជន៍ និងកាលវិភាគអាចបត់បែនបាន។

**ការសម្រេចចិត្ត៖** គប្បីទាក់ទាញការចូលរួមរបស់សមាជិកគ្រួសារសិស្សក្នុងដំណើរការសម្រេចចិត្តអភិបាលកិច្ច និងសកម្មភាពតស៊ូមតិរបស់សាលារៀនតាមរយៈក្រុមប្រឹក្សាសាលារៀន ឬក្រុមកែលម្អសាលារៀន គណៈកម្មការ និងអង្គភាពផ្សេងៗទៀត។

**សហការជាមួយសហគមន៍៖** សម្របសម្រួលធនធាន និងសេវាកម្មសម្រាប់គ្រួសារ សិស្ស និងសាលារៀនជាមួយក្រុមសហគមន៍ ដែលរួមមានអាជីវកម្ម ភ្នាក់ងារអង្គការវប្បធម៌ និងស៊ីវិល និងសកលវិទ្យាល័យ។

សម្គាល់៖ ឯកសារនេះត្រូវបានផលិតឡើងក្រោមជំនួយថវិការបស់សហភាពអឺរ៉ុប រដ្ឋាភិបាលប៊ែលហ្ស៊ិក និងរដ្ឋាភិបាលហ្លែមីស៍។ខ្លឹមសារនៃឯកសារនេះស្ថិតក្រោមការទទួលខុសត្រូវរបស់VVOB – ការអប់រំដើម្បីអភិវឌ្ឍន៍ហើយមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ទាំងនេះទេ ។

រៀបចំដោយ

vvob education for development

ឧបត្ថម្ភដោយ

Belgium partner in development

Flanders State of the Art